**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***

ខេត្តបាត់ដំបង

ក្រុងបាត់ដំបង

សង្កាត់ព្រែកព្រះស្ដេច

លេខ០២៤.សពស.រប

# សេចក្ដីណែនាំ

## ស្ដីពី ការចូលរួមកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង

**យោង** ៖ - ស្មារតីនៃអង្គប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាសង្កាត់ព្រែកព្រះស្ដេចថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០១៥

ក្រុមប្រឹក្សាសង្កាត់ព្រែកព្រះស្ដេច សូមជូនដំណឹង និងណែនាំដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់ទាំងមូលអោយបានជ្រាបថា ដើម្បីទប់ស្កាត់អំពើហិង្សា និងលើកកម្ពស់សណ្ដាប់ធ្នាប់សហគមន៍ ក្រុមប្រឹក្សាសង្កាត់ សូមធ្វើការណែនាំដូចខាងក្រោម៖

1. បុគ្គលគ្រប់រូប សូមកុំប្រើក្មេងក្រោមអាយុ ១៨ឆ្នាំ ទៅទិញគ្រឿងស្រវឹង
2. សូមអាជីវករ កុំលក់គ្រឿងស្រវឹងឱ្យក្មេងក្រោមអាយុ ១៨ឆ្នាំ
3. សូមក្មេងក្រោមអាយុ ១៨ឆ្នាំ កុំទិញ និងប្រើប្រាស់គ្រឿងស្រវឹង
4. សូមកុំលក់គ្រឿងស្រវឹងនៅក្នុង ឫក្បែរសាលារៀន មន្ទីរពេទ្យ និងវត្តអារាម
5. សូមកុំប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងវត្តអារាម មន្ទីរពេទ្យ និងសាលារៀន
6. សូមកុំលើកផ្ទាំងប៉ាណូ ស្លាយីហោ ផ្សព្វផ្សាយផលិតផលគ្រឿងស្រវឹងនៅក្បែរសាលារៀន មន្ទីរពេទ្យ និងវត្តអារាម។

ក្រោយពីទទួលបានការនូសេចក្ដីណែនាំខាងលើ រដ្ឋបាលស្កាត់សង្ឃឹម និងជឿជាក់យ៉ាងមុតមាំថាប្រជាពលរដ្ឋនៃសង្កាត់ទាំងមូលនឹងចូលរួមសហការណ៍អនុវត្តន៍តាមសេចក្ដីណែនាំខាងលើអោយមានប្រសិទ្ធភាពជាក់ជាមិនខាន។

សេចក្ដីណែនាំនេះ មានប្រសិទ្ធភាព និងអនុវត្តន៍ក្រោយពេលការចុះហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាសង្កាត់ និងចៅសង្កាត់ តទៅ។

ព្រែកព្រះស្ដេច ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦

ប្រធានក្រុមប្រឹក្សា និងជាចៅសង្កាត់

សោ ហ៊ុន

<u>ចម្លងជូន</u>

-លោកអភិបាលក្រុងបាត់ដំបង

(ដើម្បីជូនជ្រាប)

-មេភូមិ គ្រប់ភូមិ (ដើម្បីសហការ និងផ្សព្វផ្សាយ)

-ឯកសារ កាលប្បវត្តិ